# ព្រះបន្ទូលនៃជីវិត

១ ពត.២:២-៣ នោះត្រូវឱ្យសង្វាតរក ទឹកដោះសុទ្ធនៃព្រះបន្ទូលវិញ ដូចជាទារកដែលទើបនឹងកើត ដើម្បីឱ្យអ្នករាល់គ្នាបាន ចម្រើនធំឡើង ដរាបដល់បានសង្គ្រោះ គឺបើអ្នករាល់គ្នាបានភ្លក់ឱ្យដឹងថា ព្រះអម្ចាស់ទ្រង់ល្អមែន។

## ព្រះបន្ទូលនៃជីវិត

ព្រះគម្ពីរគឺជាសៀវភៅតែមួយគត់ ដែលឈរនៅលំដាប់ខ្ពស់ជាងសៀវភៅផ្សេងៗទៀត។ សៀវភៅនេះត្រូវបានគេអាន ច្រើនជាងគេបំផុត និងត្រូវបានបកប្រែជាងមួយពាន់ភាសា ច្រើនជាងសៀវភៅផ្សេងៗទៀតនៅក្នុងពិភពលោកនោះ។ ព្រះគម្ពីរ គឺជាសេចក្តីបណ្តាល ពីព្រោះវាជាព្រះបន្ទូលនៃជីវិត និងជាព្រះបន្ទូលដ៏រស់។ មូលហេតុដែលថា ព្រះបន្ទូលនេះរស់ ពីព្រោះ ព្រះបន្ទូលនេះ ជាសេចក្តីបើកសម្តែងអំពីព្រះដ៏មានព្រះជន្មរស់នៅ។ បំណងនៅក្នុងផែនការគ្រប់គ្រងរបស់ព្រះ គឺចែកចាយ ព្រះគ្រិស្ត ចូលមកក្នុងយើងរាល់គ្នា ហើយដើម្បីចែកចាយចូលមកក្នុងយើងបាន គឺត្រូវតែមានមធ្យោបាយ។ ព្រះគម្ពីរ គឺជាម ធ្យោបាយដែលព្រះជាម្ចាស់ប្រើដើម្បីចែកចាយព្រះគ្រិស្ត ចូលមកក្នុងយើង។

## មធ្យោបាយពីរយ៉ាងដើម្បីប៉ះពាល់ព្រះគម្ពីរ

មានមធ្យោបាយពីរយ៉ាងដើម្បីប៉ះពាល់ព្រះគម្ពីរ ផ្លូវនៅផ្នែកខាងក្រៅ និងផ្លូវនៅផ្នែកខាងក្នុង។ ផ្លូវនៅផ្នែកខាងក្រៅដើម្បី ប៉ះពាល់ព្រះគម្ពីរ គឺហ្វឹកហាត់គំនិតរបស់យើងដើម្បីយល់រីឯផ្លូវនៅផ្នែកខាងក្នុងវិញ គឺប្រើវិញ្ញាណរបស់យើង ដោយមិនត្រឹមតែ ឱ្យបានយល់ ប៉ុន្តែថែមទាំងឱ្យបានប៉ះពាល់វិញ្ញាណ និងទទួលបានជីវិតផ្គត់ផ្គង់ ។.

ពេលខ្លះយើងមិនសូវយល់នូវអ្វីដែលយើងបានអានទេហើយពេលខ្លះទៀតយើងយល់ដែរ ប៉ុន្តែយើងនៅតែមិនអាច និយាយចេញនូវអ្វីដែលយើងបានមើលឃើញនោះ។ ប្រហែលជាយើងអាចនិយាយថា៖ " សរសើរតម្កើងព្រះអង្គ ព្រឹកនេះខ្ញុំ ទទួលបានខ្លះៗដែរ ប៉ុន្តែខ្ញុំមិនមានពាក្យអធិប្បាយទេ!" នេះជាមធ្យោបាយត្រឹមត្រូវ។ មធ្យោបាយត្រឹមត្រូវនៃការប៉ះពាល់ព្រះ គម្ពីរ គឺប៉ះពាល់ព្រះអង្គទ្រង់ផ្ទាល់។ យើងមិនត្រូវញែកព្រះគម្ពីរ ចេញពីព្រះអម្ចាស់ឡើយ រាល់ពេលណាដែលយើងបើកព្រះ គម្ពីរ យើងត្រូវតែបើកមាត់ និងបើកវិញ្ញាណរបស់យើង និយាយអ្វីខ្លះទៅកាន់ព្រះអង្គ។ យើងអាចនិយាយដូច្នេះថា៖ " ព្រះ អម្ចាស់អើយ! អូ ព្រះអម្ចាស់យេស៊ូ! "

## មកឯព្រះបន្ទូលដើម្បី "ភ្លក់" ព្រះអង្គមើល

ព្រះបន្ទូលមិនមែនត្រឹមតែសម្រាប់ឱ្យយើងសិក្សា ឬរៀនប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ឱ្យយើងភ្លក់ផងដែរ។ ផ្លូវដែលព្រះអង្គ ចិញ្ចឹមដល់រូបកាយរបស់ទ្រង់ គឺតាមរយៈព្រះបន្ទូលរបស់ទ្រង់។ ប្រសិនបើយើងចង់អំណរព្រះអង្គ និងទទួលការចិញ្ចឹមពីព្រះ អង្គ យើងត្រូវតែមកឯព្រះបន្ទូលដើម្បីភ្លក់ព្រះអង្គ។

## មុខងារសំខាន់របស់ព្រះគម្ពីរ គឺចែករំលែកព្រះថាថ្មីរិតចូលមកក្នុងយើង

មុខងារសំខាន់របស់ព្រះគម្ពីរ គឺចែករំលែកព្រះនជាជីវិតចូលមកក្នុងយើង និងចិញ្ចឹមយើងដោយជីវិត។ ព្រះគម្ពីរមិនត្រឹម តែជួយឱ្យយើងស្គាល់ព្រះជាម្ចាស់ និងសេចក្តីស្រឡាញ់របស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចែករំលែកព្រះជាម្ចាស់ផ្ទាល់ ចូល មកក្នុងយើងផងដែរ។ រាល់ពេលណាដែលយើងអានព្រះគម្ពីរ យើងមិនចាំបាច់ព្យាយាមស្គាល់ឬឱ្យយល់នោះទេ ប៉ុន្តែយើងត្រូវ ទទួលយកធាតុដើមរបស់ព្រះចូលមកក្នុងយើង ដូចជាយើងបរិភោគអាហារ។ បន្ទាប់មកសារជាតិនៃអាហារនេះ នឹងរលាយ ជ្រាបចូលទៅក្នុងគ្រប់ផ្នែកនៃសារពាង្គកាយរបស់យើង។

# សូមកាច់នំបុ័ងជីវិត

(ឥ. 806)




២. ទ្រង់ជានំបុ័ងជីវិតដែលខ្ញុំឃ្លានណាស់ ព្រះបន្ទូលទ្រង់បានជួយសង្គ្រោះខ្ញុំច្បាស់
សូមឲ្យខ្ញុំបានអាស្រ័យនៅចំពោះទ្រង់ ដោយក្តីស្រឡាញ់ខ្ញុំចូលជិតជាប់ព្រះអង្គ ។

៣. សូមប្រោសឲ្យខ្ញុំបានភ្លឺយល់សេចក្តីពិត ដូចបានប្រោសដល់ពួកសិស្សកាលទ្រង់គង់ជិត
នោះអស់ចំណងនៃបាបនឹងត្រូវផ្តាច់ចេញ ហើយខ្ញុំនឹងមានចិត្តបរិសុទ្ធពោរពេញ ។

៤. សូមបង្ហាត់ឲ្យខ្ញុំរស់ថ្វាយដល់ព្រះអង្គ ដូចពួកសិស្សពីដើមដែលមានចិត្តស្មោះត្រង់
នោះខ្ញុំនឹងអាចឈ្នះបាបរួចពីទុក្ខទោស ដោយប្រកបនឹងព្រះដ៏ជាអង្គសង្គ្រោះ ។

៥. ឱសូមចាត់ព្រះវិញ្ញាណមកសណ្ឋិតផង ទ្រង់នឹងបំពេញចិត្តឲ្យបានហ្មត់ហ្មង
ហើយបង្ហាញសេចក្តីពិតក្នុងព្រះបន្ទូល នោះនឹងឃើញព្រះអង្គក្នុងគម្ពីរទាំងមូល ។